**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៨១១ ព.ណ.កសម

ថ្ងៃ ច័ន្ទ ៨កើត ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០២២

**ជម្រាបមក**
**លោក/លោកស្រីប្រធាន ក្រុមហ៊ុន ឌី-ស្តារ គ្រុប**

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលថែរក្សាសម្រស់ គ្រឿងសម្អាងក្រែម គ្រឿងសម្អាង ក្រែមសម្រាប់ស្បែក ក្រែមធ្វើឱ្យស្បែកស ឡេប្រភេទគ្រឿងសម្អាង គ្រឿងសម្អាងថែរក្សាស្បែក ឡេការពារកំដៅថ្ងៃ ក្រែមលាបមុខ ក្រែមបំប៉ន ឡេផ្តល់ជាតិសំណើម ក្រែមសំរាប់បំប៉នស្បែក ក្រែមសំអាត ឡេសំអាតស្បែក និងឡេផលិតពីទឹកដោះគោម៉ាក OBAGI MEDICAL ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ឌី-ស្តារ គ្រុប**។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ឌី-ស្តារ គ្រុប** ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២២
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ៣០៣៤ ព.ណ កសប ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០២០
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Obagi Cosmeceuticals LLC ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣២០៧៩/០៩ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលថែរក្សាសម្រស់ គ្រឿងសម្អាងក្រែម គ្រឿងសម្អាង ក្រែមសម្រាប់ស្បែក ក្រែមធ្វើឱ្យស្បែកស ឡេប្រភេទគ្រឿងសម្អាង គ្រឿងសម្អាងថែរក្សាស្បែក ឡេការពារកំដៅថ្ងៃ ក្រែមលាបមុខ ក្រែមបំប៉ន ឡេផ្តល់ជាតិសំណើម ក្រែមសំរាប់បំប៉នស្បែក ក្រែមសំអាត ឡេសំអាតស្បែក និងឡេផលិតពីទឹកដោះគោពាក់ម៉ាកខាងលើ ក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុន **ឌី-ស្តារ គ្រុប** ដែលទទួលបានពីក្រុមហ៊ុន Obagi Cosmeceuticals LLC ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាកដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតបន្តសុពលភាពកត់ត្រានេះ មានសុពលភាពត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២៣ ដោយគិតចាប់ពីថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០២២ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Obagi Cosmeceuticals LLC ដែលជាម្ចាស់ម៉ាក ។

និតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*__ចម្លងជូន:__*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ* ***សម្តេចអគ្គមហាសេនាបតីតេជោ*** *នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម* ***ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*